២០១៥ 10/11 15

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

ទីស្តីការគណៈរដ្ឋមន្ត្រី

លេខ ១៧៤៥ សជណ.កស

ក្រសួងពាណិជ្ជកម្ម
ចូល លេខ 8179 នរប
ថ្ងៃទី 10 ខែ 11 ឆ្នាំ ២០១៥
បញ្ជូនទៅ

រាជធានីភ្នំពេញ ថ្ងៃទី ០៣ ខែ វិច្ឆិកា ឆ្នាំ២០១៥

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

**សូមជម្រាបជូន**

**ឯកឧត្តម រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

**កម្មវត្ថុ៖** ករណីរបាយការណ៍ស្តីពីការចិញ្ចឹមត្រីឆ្តោ និងត្រីរ៉ស់ ។

**យោង** ៖- លិខិតលេខ ៧០៩១ កសក ចុះថ្ងៃទី២៧ ខែតុលា ឆ្នាំ២០១៥ របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

- ចំណារ **សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី** ចុះថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ២០១៥។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ទីស្តីការគណៈរដ្ឋមន្ត្រី សូមជម្រាបជូនឯកឧត្តម ជ្រាបថា រាជរដ្ឋាភិបាលឯកភាពតាមលទ្ធផលអង្គប្រជុំរួមគ្នារវាងសាកលវិទ្យាល័យ Can Tho ប្រទេសវៀតណាម សាកលវិទ្យាល័យ Connecticut និង Arkansas របស់សហរដ្ឋអាមេរិក និងសាកលវិទ្យាល័យ Telca របស់ឈីលី និងការសិក្សារបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ស្តីពីការចិញ្ចឹមត្រីឆ្តោ និងត្រីរ៉ស់ ដូចខាងក្រោម៖

- មិនឱ្យមានការចិញ្ចឹមត្រីឆ្តោ ព្រោះត្រីឆ្តោមិនស៊ីចំណីសិប្បនិម្មិតទេ គឺស៊ីតែកូនត្រីធម្មជាតិ ដែលនាំឱ្យមានបទល្មើសនេសាទផង និងបាត់បង់ធនធានជលផលផង។
- មិនឱ្យចិញ្ចឹមត្រីរ៉ស់បន្តទៅទៀត។ ព្រោះការចិញ្ចឹមត្រីរ៉ស់នៅពេលនេះគឺនៅមានហានិភ័យខ្ពស់នៅឡើយ។

សេចក្តីដូចបានជម្រាបជូនខាងលើ សូមឯកឧត្តមមេត្តាជ្រាប និងចាត់ចែងអនុវត្តតាមការគួរ។

**ជ.រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**
**រដ្ឋលេខាធិការ**

**ប៊ុន_អ៊ុយ**

**ចម្លងជូន:**
- ក្រសួងមហាផ្ទៃ
- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ក្រសួងពាណិជ្ជកម្ម
- ក្រសួងបរិស្ថាន
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី សុខ អាន
- រដ្ឋបាលជលផល
- ឯកសារ-កាលប្បវត្តិ